**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

**លេខ** ១៣៩ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៧

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ សំដៅធានាដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយ ប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងកាត់បន្ថយភាពក្រីក្រ

- ជំរុញការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍របស់ថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់
- សហការជាមួយ ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងបណ្តាប្រទេសជិតខាងក្នុងតំបន់GMS ដើម្បីសិក្សា ស្រាវជ្រាវ រៀបចំគម្រោងអភិវឌ្ឍ និងជំរុញកិច្ចសហប្រតិបត្តិការអភិវឌ្ឍទេសចរណ៍ក្នុងក្របខណ្ឌតំបន់ ដូចជា ត្រីកោណអភិវឌ្ឍ ត្រីកោណមរកត ច្រករបៀងទេសចរណ៍ភាគខាងត្បូង តំបន់ផ្សេងៗទៀត និងធ្វើសមាហរណកម្មផែនការអភិវឌ្ឍទេសចរណ៍ជាតិ ជាមួយផែនការទេសចរណ៍អាស៊ាន និងអន្តរជាតិនានា។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍** ចំណុះអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារសិក្សាស្រាវជ្រាវ និងរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍។

**នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិ
- សហការរៀបចំផែនការទេសចរណ៍ផ្ទះទីពីរ ទេសចរណ៍វ័យចំណាស់ និងប្រភេទទេសចរណ៍ផ្សេងទៀត និងផែនការប្រើប្រាស់ដីធ្លីសម្រាប់វិស័យទេសចរណ៍
- ពិគ្រោះយោបល់លើគោលនយោបាយអាកាសចរណ៍ ទិដ្ឋាការ គោលនយោបាយការប្រើប្រាស់ដីធ្លី ផែនការរូបវ័ន្ត និងផែនការអភិវឌ្ឍន៍
- សហការរៀបចំ បង្កើត និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍ទេសចរណ៍ដើម្បីត្រួតពិនិត្យ កែលម្អ និងរក្សាបានការអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជាប្រកបដោយគុណភាព និរន្តរភាព និងការទទួលខុសត្រូវ
- សហការរៀបចំយុទ្ធសាស្ត្រជំរុញការកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងបណ្តាប្រទេសក្នុងតំបន់ដើម្បីសិក្សាស្រាវជ្រាវ រៀបចំគម្រោងអភិវឌ្ឍន៍ និងជំរុញកិច្ចសហប្រតិបត្តិការទេសចរណ៍ក្នុងក្របខណ្ឌតំបន់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញ និងវាយតម្លៃការអនុវត្តផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍
- ជាលេខាធិការដ្ឋានរបស់គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍
- ផ្តល់យោបល់ផ្នែកជំនាញដល់ការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងផ្នែកឯកជនដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពរាល់គម្រោងអភិវឌ្ឍន៍នានាដែលបម្រើឱ្យវិស័យទេសចរណ៍ឱ្យស្របតាមផែនការអភិវឌ្ឍន៍ទេសចរណ៍
- ស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ និងផ្នែកពាក់ព័ន្ធដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍នៅកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។



ហត្ថលេខា

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ មានការិយាល័យចំណុះចំនួន ០៧(ប្រាំពីរ) ដូចខាងក្រោម៖

១-ការិយាល័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍

២-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ

៣-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត

៤-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ

៥-ការិយាល័យមហាអនុតំបន់មេគង្គ (GMS)

៦-ការិយាល័យអភិវឌ្ឍន៍បរិស្ថានទេសចរណ៍

៧-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ ៖

**១-ការិយាល័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- សិក្សាស្រាវជ្រាវ រៀបចំផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការអភិវឌ្ឍទេសចរណ៍នៅថ្នាក់ជាតិ ថ្នាក់តំបន់ និងផ្តល់យោបល់ជំនាញដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា
- ជំរុញការរៀបចំគម្រោងអភិវឌ្ឍទេសចរណ៍ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់គម្រោងអាទិភាព ស្វែងរកការជួយឧបត្ថម្ភគាំទ្រនិងរៀបចំរបាយការណ៍ ស្តីពីការអនុវត្តគម្រោងទេសចរណ៍
- ផ្តល់យោបល់ផ្នែកជំនាញក្នុងការរៀបចំ និងជំរុញការអនុវត្ត ផែនការអភិវឌ្ឍន៍ទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការ សិក្សាស្រាវជ្រាវ វិភាគលើទិន្នន័យទេសចរណ៍ សម្រាប់ធ្វើការព្យាករណ៍ទេសចរណ៍ សិក្សាតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ ដើម្បីការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍
- ធ្វើការសម្របសម្រួលរៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលារបស់គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ និងកិច្ចប្រជុំជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន
- ទំនាក់ទំនងសម្របសម្រួល និងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ ផែនការអភិវឌ្ឍន៍ ពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ប្រកបដោយប្រសិទ្ធិភាព
- រៀបចំបូកសរុបរបាយការណ៍ការងារ ស្ថានភាពទេសចរណ៍ លើកយោបល់ ឬដំណោះស្រាយព្រមទាំងផែនការនានា និងផែនការហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ ជូនប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ និងរាជរដ្ឋាភិបាល
- រៀបចំគម្រោងផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍

- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អង្គភាពពាក់ព័ន្ធនៃក្រសួងទេសចរណ៍ រៀបចំផែនការ បណ្តុះបណ្តាលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ទេសចរណ៍ដល់មន្ត្រីទេសចរណ៍ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកពាក់ព័ន្ធ
- ចូលរួមសកម្មភាពដែលពាក់ព័ន្ធនឹងផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ដូចជាសន្និសីទ វេទិកា កិច្ចប្រជុំ ការបណ្តុះបណ្តាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស
- ចូលរួមសហការជាមួយការិយាល័យផ្ទៃក្នុងនាយកដ្ឋាន និងនាយកដ្ឋានជំនាញនៃក្រសួងទេសចរណ៍ ក្នុងការចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ទិន្នន័យដើម្បីធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ទេសចរណ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់ជាតិ ថ្នាក់តំបន់ស្របតាមស្ថានភាព នៃការវិវត្តន៍វិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាជាក់ស្តែង។

**២-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ** មានតួនាទី និងភារកិច្ចៈ
- រៀបចំផែនការអភិវឌ្ឍន៍ និងផែនការយុទ្ធសាស្ត្រទេសចរណ៍ សម្រាប់តំបន់ឆ្នេរ ខេត្តកែប កំពត ព្រះសីហនុ និងខេត្តកោះកុង នៃព្រះរាជាណាចក្រកម្ពុជា
- សិក្សាស្រាវជ្រាវផ្តល់យោបល់លើផលប៉ះពាល់លើគម្រោងអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរ និងគម្រោងអភិវឌ្ឍទេសចរណ៍នានារបស់ផ្នែកសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវរៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ជាពិសេសទេសចរណ៍តំបន់ឆ្នេរ ដោយធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា
- សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីប្រកាសរួម ស្តីពីការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ ដែលមានការទទួលខុសត្រូវរួមគ្នា
- សិក្សាស្រាវជ្រាវ វិភាគលើទិន្នន័យទេសចរណ៍ សម្រាប់ធ្វើការព្យាករណ៍ទេសចរណ៍ សិក្សាតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ
- ចូលរួមសកម្មភាពដែលពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ ដូចជាសន្និសីទ វេទិកា កិច្ចប្រជុំ ការបណ្តុះបណ្តាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស
- សម្របសម្រួលជាមួយផ្នែកដែលពាក់ព័ន្ធ និងគ្រប់គ្រងសេវាកម្មទេសចរណ៍ក្នុងក្របខណ្ឌទេសចរណ៍តំបន់
- ចូលរួមសហការជាមួយនាយកដ្ឋានជំនាញនៃក្រសួងទេសចរណ៍ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា លើគំរោងការពារបរិស្ថានតាមរយៈសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ
- រៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគែលម្អផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ
- ធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ ស្របតាមការវិវត្តន៍វិស័យទេសចរណ៍ជាតិជាក់ស្តែង
- រៀបចំសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលអប់រំចំណេះដឹងដល់មន្ត្រីទេសចរណ៍ ស្តីពីផែនការអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រទេសចរណ៍តំបន់ឆ្នេរ។

**៣-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត** មានតួនាទី និងភារកិច្ចៈ
- រៀបចំយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍន៍ទេសចរណ៍សម្រាប់តំបន់ភូមិភាគឦសាន្ត ខេត្តរតនគីរី មណ្ឌលគីរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តកំពង់ចាម
- ផ្តល់យោបល់លើផលប៉ះពាល់លើគម្រោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត និងគម្រោងអភិវឌ្ឍន៍ទេសចរណ៍នានារបស់ផ្នែកសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល

- សហការជាមួយក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវរៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ជាពិសេសទេសចរណ៍តំបន់ភូមិភាគឦសាន្ត ដោយធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា
- សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ក្នុងការរៀបចំសេចក្ដីប្រកាសរួម ស្ដីពីការរៀបចំគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត ដែលមានការទទួលខុសត្រូវរួមគ្នា
- វិភាគលើទិន្នន័យទេសចរណ៍ សម្រាប់ធ្វើការព្យាករណ៍ទេសចរ សិក្សាតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ ដើម្បីការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត
- ចូលរួមសកម្មភាពដែលពាក់ព័ន្ធ នឹងការរៀបចំយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត ដូចជាសន្និសីទ វេទិកា កិច្ចប្រជុំ ការបណ្ដុះបណ្ដាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ផ្លាស់ប្ដូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស
- ចូលរួមសហការជាមួយនាយកដ្ឋានជំនាញនៃក្រសួងទេសចរណ៍ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា លើគំរោងការពារបរិស្ថានតាមរយៈសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត
- សម្របសម្រួលជាមួយផ្នែកដែលពាក់ព័ន្ធ និងគ្រប់គ្រងសេវាកម្មទេសចរណ៍ក្នុងក្របខណ្ឌទេសចរណ៍តំបន់ភូមិភាគឦសាន្ត
- រៀបចំសិក្ខាសាលា និងបើកវគ្គបណ្ដុះបណ្ដាលអប់រំចំណេះដឹងដល់មន្ត្រីទេសចរណ៍ ស្ដីពីផែនការអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន្ត។

**៤-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ** មានតួនាទី និងភារកិច្ចៈ

- សិក្សាស្រាវជ្រាវ រៀបចំយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ សម្រាប់ខេត្តសៀមរាប កំពង់ធំ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ
- ផ្ដល់យោបល់លើផលប៉ះពាល់លើគម្រោងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ នូវគម្រោងអភិវឌ្ឍន៍ទេសចរណ៍នានារបស់ផ្នែកសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវរៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ ជាពិសេសទេសចរណ៍សៀមរាប និងតំបន់ជុំវិញ ដោយធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ក្នុងការរៀបចំសេចក្ដីប្រកាសរួម ស្ដីពីការរៀបចំគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ ដែលមានការទទួលខុសត្រូវរួមគ្នា
- សម្របសម្រួលជាមួយផ្នែកដែលពាក់ព័ន្ធ និងគ្រប់គ្រងសេវាកម្មទេសចរណ៍ក្នុងក្របខណ្ឌទេសចរណ៍សៀមរាប និងតំបន់ជុំវិញ
- វិភាគលើទិន្នន័យទេសចរណ៍ សម្រាប់ធ្វើការព្យាករណ៍ទេសចរ សិក្សាតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ ដើម្បីការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ
- ចូលរួមសកម្មភាពដែលពាក់ព័ន្ធ នឹងការរៀបចំយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញដូចជា សន្និសីទ វេទិកា កិច្ចប្រជុំ ការបណ្ដុះបណ្ដាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ផ្លាស់ប្ដូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស
- រៀបចំសិក្ខាសាលា និងបើកវគ្គបណ្ដុះបណ្ដាលអប់រំចំណេះដឹងដល់មន្ត្រីទេសចរណ៍ ស្ដីពីផែនការអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ។

**៥-ការិយាល័យមហាអនុតំបន់មេគង្គ** មានតួនាទី និងភារកិច្ចៈ

- សម្របសម្រួល ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកមហាអនុតំបន់មេគង្គ ការិយាល័យសម្របសម្រួលទេសចរណ៍មេគង្គ (MTCO) ក្នុងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ក្នុងមហាអនុតំបន់មេគង្គ

- សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រទេសជាសមាជិក ក្នុងការអភិវឌ្ឍទេសចរណ៍ក្នុងក្របខណ្ឌតំបន់ត្រីកោណ ដូចជាតំបន់ត្រីកោណមរកត (កម្ពុជា-ឡាវ-ថៃ)តំបន់ត្រីកោណអភិវឌ្ឍន៍ (កម្ពុជា-ឡាវ-វៀតណាម) ច្រករបៀងទេសចរណ៍ភាគខាងត្បូង (កម្ពុជា-ថៃ-វៀតណាម) មេគង្គ-ជប៉ុន និងតំបន់ផ្សេងៗទៀត ដោយធ្វើសមាហរណកម្មជាមួយផែនការអភិវឌ្ឍន៍របស់ប្រទេសជាសមាជិកក្នុងតំបន់
- ចូលរួមសកម្មភាពទេសចរណ៍ដែលពាក់ពន្ធ័នឹងមហាអនុតំបន់មេគង្គ ដូចជាកិច្ចប្រជុំ ការបណ្តុះបណ្តាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ទាំងក្នុង និងក្រៅប្រទេស
- សហប្រតិបត្តិការជាមួយប្រទេសសមាជិកមហាអនុតំបន់មេគង្គ ជាពិសេសប្រទេសជិតខាងក្នុងការធ្វើឱ្យប្រសើរឡើងក្នុងការសម្របសម្រួលការធ្វើដំណើរឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិ។

**៦-ការិយាល័យអភិវឌ្ឍន៍បរិស្ថានទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- សិក្សាស្រាវជ្រាវ រៀបចំផែនការយុទ្ធសាស្ត្រ លើកិច្ចការពារបរិស្ថាន ក្នុងវិស័យទេសចរណ៍
- ផ្តល់យោបល់លើផលប៉ះពាល់បរិស្ថានជាមួយក្រសួងបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ លើគម្រោងអភិវឌ្ឍន៍ទេសចរណ៍នានា របស់ផ្នែកសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- ជំរុញលើកទឹកចិត្ត និងគាំទ្រក្នុងការបង្កើតបណ្តាញបរិស្ថានទេសចរណ៍ នៅគ្រប់កម្រិត ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍
- សិក្សាស្រាវជ្រាវរៀបចំស្តង់ដារ និងបទដ្ឋានគតិយុត្តសម្រាប់ការអភិវឌ្ឍទេសចរណ៍នៅកម្ពុជា
- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ អង្គភាពពាក់ព័ន្ធនៃក្រសួងទេសចរណ៍ រៀបចំផែនការ បណ្តុះបណ្តាល ស្តីពីផលប៉ះពាល់បរិស្ថាន ដល់មន្ត្រីទេសចរណ៍ថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្នែកពាក់ព័ន្ធ
- សហការជាមួយក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធ ក្នុងការសិក្សាស្រាវជ្រាវ លើការងារបរិស្ថានក្នុងវិស័យទេសចរណ៍
- តាមដានត្រួតពិនិត្យ និងវាយតំលៃគុណភាពបរិស្ថាននៅតាមតំបន់ និងរមណីយដ្ឋានទេសចរណ៍។

**៧-ការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ** មានតួនាទី និងភារកិច្ចៈ

- សិក្សាស្រាវជ្រាវ រៀបចំយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ សម្រាប់រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ និងខេត្តស្វាយរៀង
- ផ្តល់យោបល់លើផលប៉ះពាល់លើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ និងគម្រោងអភិវឌ្ឍន៍ទេសចរណ៍នានារបស់ផ្នែកសាធារណៈ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- សហការជាមួយក្រសួង ស្ថាប័ន និងផ្នែកពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវរៀបចំ និងអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់តំបន់ ជាពិសេសទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ ដោយធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាន និងផែនការទេសចរណ៍អន្តរជាតិនានា
- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីប្រកាសរួម ស្តីពីការរៀបចំគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ ដែលមានការទទួលខុសត្រូវរួមគ្នា
- សម្របសម្រួលជាមួយផ្នែកដែលពាក់ព័ន្ធ និងគ្រប់គ្រងសេវាកម្មទេសចរណ៍ក្នុងក្របខណ្ឌទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ
- វិភាគលើទិន្នន័យទេសចរណ៍ សម្រាប់ធ្វើការព្យាករណ៍ទេសចរ សិក្សាតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ ដើម្បីការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ
- ចូលរួមសកម្មភាពដែលពាក់ព័ន្ធ នឹងការរៀបចំយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ ដូចជាសន្និសីទ វេទិកា កិច្ចប្រជុំ ការបណ្តុះបណ្តាល សិក្ខាសាលា ក៏ដូចជាទស្សនកិច្ចសិក្សាស្រាវជ្រាវ ផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុង និងក្រៅប្រទេស
- រៀបចំសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលអប់រំចំណេះដឹងដល់មន្ត្រីទេសចរណ៍ ស្តីពីផែនការអភិវឌ្ឍន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ភ្នំពេញ និងតំបន់ជុំវិញ។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឱ្យនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ មានតួនាទី និងភារកិច្ចៈ

- ធ្វើកំណត់ហេតុប្រជុំដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ខ្លួន
- រៀបចំគម្រោងផែនការសកម្មភាពការងារ និងថវិកាចំណាយផ្សេងៗ និងប្រចាំឆ្នាំរបស់ខ្លួនជូនប្រធាននាយកដ្ឋាន
- ណែនាំដល់អង្គភាពទេសចរណ៍គ្រប់កម្រិតក្នុងការរៀបចំយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព និងគម្រោងអភិវឌ្ឍន៍ទេសចរណ៍
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ